# គោលគំនិតសំខាន់ដើម្បីយល់ពី
# ព្រះពុទ្ធ

- ព្រះអង្គជាមនុស្សព្រោះ កើតក្នុងសង្គមមនុស្ស រស់នៅក្នុងសង្គមមនុស្ស ដឹកនាំសង្គមមនុស្ស មានបញ្ហាជាមួយសង្គមមនុស្ស បានទទួលការរិះគន់ទិតៀនអាឃាតព្យាបាទពីសង្គមមនុស្ស ស្លាប់ក្នុងសង្គមមនុស្ស ដូច្នេះព្រះអង្គទ្រង់ជ្រាបពីមនុស្សគ្មានខ្វះចន្លោះអ្វីឡើយ ។
- ព្រះអង្គទ្រង់កើតក្នុងលោក គង់នៅក្នុងលោក តែមិនប្រឡាក់ដោយលោកឡើយ ដូចជាឈូកមិនជាប់ប្រឡាក់ដោយទឹកដូច្នោះឯង ។
- ព្រះអង្គមិនអាចជួយនរណាឱ្យផុតពីអន្លង់ទុក្ខ ដែលជាផលនៃកម្មរបស់ខ្លួនបានទេ សូម្បីតែព្រះសុប្បពុទ្ធជាឪពុកក្មេក និងទេវទត្តជាប្អូនថ្លៃ ក៏ព្រះអង្គជួយមិនបានផង ប៉ុន្តែ កាលបើអ្នកទាំងនោះបានដឹងច្បាស់នូវធម៌ដ៏ប្រសើររបស់ព្រះអង្គ នឹងអាចឆ្លងនូវឱឃៈនេះបាន ។
- ព្រះអង្គជាបដិវត្តបុគ្គលផ្នែកខាងសាសនាល្បីល្បាញក្នុងប្រទេសឥណ្ឌាសម័យពុទ្ធកាល ដោយទ្រង់បានបង្វិលធម្មចក្កឱ្យវិលទៅសព្វទិសទី ដោយសន្តិវិធី ។
- ព្រះអង្គទ្រង់បើកឱ្យបរិស័ទសួរតែប្រស្នាណា ដែលមានប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងលោកខាងមុខផង ។
- ព្រះអង្គមានបំណងជាដំបូង ឱ្យមនុស្សរលាស់ខ្លួនចេញឱ្យផុតអំពីទុក្ខក្នុងវដ្តសង្សារ ហើយបន្ទាប់មក ឱ្យបាញ់ឆ្ពោះទៅរកបរមសុខ នេះជាគោលដៅធំបំផុតរបស់ព្រះអង្គ ។
- ព្រះអង្គសំដែងធម៌ចំពោះបុគ្គលបែបណាក៏ដោយ តែងសំដែងដោយប្រុងប្រយ័ត្នណាស់ មិនមែនសំដែងទាំងខ្ជីខ្ជាទេ ព្រោះព្រះអង្គមានធម៌ជាទីគោរព គឺជាអ្នកគោរពធម៌ ។
- ព្រះអង្គមានសេចក្តីស្ងប់ស្ងាត់៣យ៉ាង ដែលគ្មាននរណាប្រៀបបានស្មើនឹងព្រះអង្គឡើយគឺ ការស្ងប់ស្ងាត់កាយ ការស្ងប់ស្ងាត់ចិត្ត និងការស្ងប់ស្ងាត់កិលេស ។
- ព្រះអង្គជាអ្នកនយោបាយដ៏កំពូលឆ្លាតគ្មានពីរ ផ្នែកខាងការប្រកាសផ្សាយព្រះធម៌ឱ្យបានជោគជ័យ និងឆាប់រហ័ស គឺផ្សាយដល់រដ្ឋមគធៈជារដ្ឋធំមុនរដ្ឋតូច ដល់ស្តេចពិម្ពិសារជាស្តេចធំមុនស្តេចតូច ដល់មេលទ្ធិធំៗមុនអ្នកតូចតាច ដល់អ្នកចេះមុនអ្នកមិនចេះ ដល់បព្វជិតមុនគ្រហស្ថ ។

- ព្រះអង្គជាព្រះអរហន្តមុនគេបំផុត ដែលបានរាវរកព្រះអរហត្តឃើញផ្ទាល់ព្រះអង្គ ឥតមានរៀនតាមនរណា ទើបគេនាំគ្នាហៅព្រះអង្គថា ព្រះពុទ្ធ ឬ ព្រះសម្មាសម្ពុទ្ធ ។
- ព្រះអង្គមិនមែនជាអាទិទេពទេ ព្រះអង្គគ្រាន់តែជាមនុស្សអស្ចារ្យ ។ ព្រះអង្គប្រសើរវិសេស រកបុគ្គលណាប្រសើរជាងគ្មាន ។ ពុំមានមនុស្សលោកណាធ្វើការខ្លាំងក្លាដូចព្រះអង្គឡើយ ។
- ព្រះអង្គទ្រង់យល់ធម៌ច្បាស់លាស់ល្អណាស់ ទើបផ្សាយព្រះធម៌បានជោគជ័យ គឺស្គាល់ពីព្រះព្រហ្ម យល់ពីព្រះព្រហ្ម ច្បាស់ជាងពួកព្រាហ្មណ៍ដែលចាត់ទុកព្រះព្រហ្មថាជាឪបង្កើតរបស់ពួកគេ ។
- ព្រះអង្គទ្រង់ត្រាស់ថា ភ្លើងមិនឋិតនៅក្នុងទឹក ខ្លឹមមិនឋិតនៅក្នុងដើមចេក ពូជមិនដុះលើថ្មភ្នំ ដង្កូវមិនឋិតនៅក្នុងឱសថ សេចក្ដីក្រោធមិនកើតក្នុងព្រះពុទ្ធ ។
- ព្រះអង្គពុំដែលបានដឹកនាំបុគ្គលណា ឱ្យសោះអង្គើយ ឱ្យខ្ជិលច្រអូស ឱ្យបង្អន់សេចក្ដីប្រឹងប្រែង ដល់ម្ដងណាទាល់តែសោះ ។ ទ្រង់តែងទេសនាពន្យល់បរិស័ទ ជាពិសេសបុរស ឱ្យមានក្ដីអង់អាច តស៊ូមានះ យកឈ្នះសត្រូវ គឺទុក្ខ ដោយព្រះវាចាថា អ្នកទាំងឡាយ កុំធ្វើជាបុរសថោកថយជាងតថាគតឡើយ ។
- ព្រះអង្គជាអ្នកត្រាស់ដឹងនូវធម៌ពិត ជាអ្នករកឃើញធម៌ ពុំមែនជាអ្នកបង្កើតធម៌ទេ ។ ធម៌មានមកយូរហើយ គឺជាធម៌ប្រចាំលោក ជាធម្មជាតិ ។
- ព្រះអង្គមានព្រះទ័យចំពោះសត្វលោក ដូចគ្នានឹងទឹកចិត្តមាតាបិតាប្រកបដោយព្រហ្មវិហារធម៌ ចំពោះបុត្រធីតា ។
- ព្រះអង្គតែងមានព្រះបន្ទូលថា សត្វលោកមានកង្វះជានិច្ច ជាទាសៈនៃកង្វះ នៃចំណង់ នៃសេចក្ដីត្រូវការរបស់ខ្លួន ។
- ព្រះអង្គមិនដែលភ្លេចត្រិះរិះពិចារណាមើលកាលៈទេសៈឡើយ មុននឹងសំដែងធម៌ ព្រោះធម៌ដែលជាវាចាពិតមានប្រយោជន៏ បើកាលៈទេសៈមិនអនុញ្ញាតឱ្យទេ ទោះជាខំនិយាយយ៉ាងណា ក៏ពុំបានផលគ្មានចំណេញអ្វីដែរ (កាលញ្ញុតា) ។
- ព្រះអង្គទ្រង់សរសើរព្រះអានន្ទថា ជាធម្មកឋិកឯកចំឡែកអស្ចារ្យណាស់ ព្រោះរាល់ពេលទេសនា ព្រះអានន្ទមិនមានការលើកដំកើងធម៌របស់ខ្លួន មិនមានការបន្តុះបង្អាប់ធម៌របស់អ្នកដទៃ មានតែការសំដែងធម៌ត្រង់ទៅរកព្រះអរហត្តតែម្យ៉ាង ។

- ព្រះអង្គពុំឱ្យតម្លៃទេវតាទេ ទ្រង់ឱ្យតម្លៃមនុស្សដែលខិតខំធ្វើការងារត្រឹមត្រូវ គឺកំណើតមនុស្សខ្ពស់ជាងកំណើតទេវតា ។ មនុស្សធ្វើល្អ គ្រាន់បើជាង ទេវតាធ្វើអាក្រក់ ។
- ព្រះអង្គបានគោរពពីសកលលោកដោយសារគុណធម៌ (៥)ប្រការគឺ ចរិយាប្រសើរបំផុត ទស្សនៈខ្ពង់ខ្ពស់បំផុត ព្រហ្មចរិយភាពប្រសើរឥតខ្ចោះ សមត្ថភាពពេញលេញ និង ឥទ្ធិពលក្នុងការដឹកនាំ ។
- ព្រះអង្គសំដែងតែបដិបទាណាដែលនាំសត្វឱ្យរួចចាកទុក្ខភ័យក្នុងវដ្តសង្សារ ព្រះអង្គមិនសំដែង បដិបទាណាដែលនាំសត្វឱ្យមានកង្វល់ក្នុងលោក ។
- ព្រះអង្គបង្ហាត់បង្រៀនមនុស្សឱ្យលះបង់នូវហេតុនៃទុក្ខ ឱ្យសាងសន្សំនូវហេតុនៃសុខ ។
- ព្រះអង្គបង្រៀនមនុស្សឱ្យ ពឹងខ្លួនឯង ពឹងកម្ម និង ពឹងធម៌ ។
- ព្រះអង្គតែងទូន្មានថា សត្វទាំងឡាយ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក ទោះធ្វើនូវកម្មណាជាបុណ្យក្តី ជាបាបក្តី រមែងជាទាយាទនៃកម្មនោះ ។
- ព្រះអង្គទ្រង់មានព្រះតម្រាស់ថា អវិជ្ជាជាមេធាតុបង្កើតនូវបាបដែលបណ្តាលឱ្យមានទុក្ខ ឯវិជ្ជាជាមេធាតុបង្កើតនូវបុណ្យដែលបណ្តាលឱ្យបានសុខ ។ ដូច្នេះបើចង់បានសុខ ត្រូវខំប្រឹងប្រែងស្ទុះស្ទាបណ្តុះនូវវិជ្ជាគ្រប់បែបយ៉ាង ។
- ព្រះអង្គតែងបញ្ជាក់ថា មូលដ្ឋានដ៏សំខាន់នៃធម៌របស់ព្រះអង្គគឺ កម្មផល ។ អំពើគ្រប់បែបយ៉ាងសុទ្ធតែមានហេតុ ។ ទ្រង់បង្រៀនឱ្យចូលចិត្ត ច្បាប់នៃកម្ម ។ ព្រះអង្គពុំបានបង្រៀនថា សេចក្តីទុក្ខរលាយបាត់ទៅដោយការបន់ស្រន់ទេ គឺបង្រៀនថា សេចក្តីសុខកើតពីកម្មល្អ សេចក្តីទុក្ខកើតពីកម្មអាក្រក់ តម្លៃមនុស្សពុំមែននៅលើវណ្ណៈទេ គឺនៅលើអំពើល្អអាក្រក់ ។
- ព្រះអង្គទ្រង់បង្ហាញផ្លូវត្រង់និងផ្តល់នូវពាក្យទូន្មានល្អៗ ដើម្បីធ្វើការងារទាំងពួងណាមួយ ឱ្យបានសម្រេចប្រយោជន៍ដូចសេចក្តីប្រាថ្នាក្នុងជីវិតលោកីយ៍នេះ ដោយមានព្រះបន្ទូលថា បើបុគ្គលធ្វើកិច្ចការណាមួយ គប្បីធ្វើកិច្ចការនោះឱ្យមែនទែន គប្បីប្រឹងប្រែងធ្វើឱ្យមាំមួន ដោយកម្លាំងបុរសរបស់ខ្លួន ដោយព្យាយាមនៃបុរសរបស់ខ្លួន ដោយពលញាណនៃបុរសរបស់ខ្លួន ដោយការប្រឹងប្រែងនៃបុរសរបស់ខ្លួន ។

- ព្រះអង្គបង្រៀនពីអរិយសច្ចៈ នាំឱ្យយល់ដោយងាយថា ខ្មោចបីសាច ទេវតា ឥន្ទ្រ ព្រហ្ម និងការស្សូត្រសំពះបួងសួងបន់ស្រន់ មិនមែនជាហេតុនៃសេចក្តីសុខទុក្ខទេ ។
- ព្រះអង្គបង្រៀនឱ្យប្រើសទ្ធាប្រកបដោយបញ្ញា គឺប្រដៅឱ្យចេះគិតពិចារណា វិនិច្ឆ័យ វែកញែក ឱ្យឃើញហេតុផលដោយខ្លួនឯងជាមុនសិន សឹមជឿតាម ។
- ព្រះអង្គប្រៀនប្រដៅឱ្យខំប្រកបអាជីវកម្មរាល់ប្រភេទ ដើម្បីរស់នៅខ្ពង់ខ្ពស់ក្នុងលោកនេះផង ខំធ្វើបុណ្យទាន ដើម្បីរស់នៅថ្លៃថ្នូរក្នុងលោកខាងមុខផង និងខំចម្រើនអរិយសច្ចធម៌ ដើម្បីសម្រេចមគ្គផលក្នុងជីវិតចុងក្រោយបង្អស់ផង ។
- ព្រះអង្គទ្រង់ដាស់តឿនទូន្មានបរិស័ទជារឿយៗថា ចូរយកខ្លួនជាទីពឹងពំនាក់របស់ខ្លួនឯង ចូរធ្វើខ្លួនឯងជាកោះជាទីជម្រកចុះ កុំយកអ្នកដទៃមកធ្វើជាជម្រកឡើយ ចូរបំពេញវត្តប្រតិបត្តិដោយខ្លួនឯងចុះ តថាគតគ្រាន់តែជាអ្នកបង្ហាញផ្លូវដល់អ្នកទេ ។
- ព្រះអង្គបង្រៀនមិនឱ្យមានពៀរ ល្អជាងដោះស្រាយពីរឿងពៀរ ។ ពេលទុក្ខមកដល់ ទើបព្យាយាមរំលត់ទុក្ខ មិនមែនជាពាក្យទូន្មានរបស់ព្រះអង្គទេ ។ ការព្យាយាមទុកជាមុន កុំឱ្យទុក្ខកើតឡើងបាន ទើបជាកិច្ចដែលត្រូវធ្វើ គឺជាព្រះពុទ្ធសាសនាសុទ្ធដែលហៅថា អរិយសច្ចៈ៤ប្រការ ។
- ព្រះអង្គមានមុខងារដ៏សំខាន់ជាចាំបាច់និងជាបន្ទាន់ គឺត្រូវដោះស្រាយបញ្ហាបច្ចុប្បន្ន ដែលកំពុងមាននៅចំពោះមុខ ឬ ដែលកំពុងជួបប្រទះ មុនបញ្ហាអនាគត ។ គិតថ្ងៃនេះមុនថ្ងៃស្អែក គិតលោកិយសុខមុនបរមសុខ ។
- ព្រះអង្គមិនដែលលើកសរសើរខ្លួនឯងថា ជាបុគ្គលគួរដល់ការបូជាទេ ទ្រង់តែងសរសើរនូវបុគ្គល ណាដែលមានវត្តប្រតិបត្តិល្អ ជាអ្នកប្រាថ្នាតិច ថាជាបុគ្គលគួរដល់ការបូជាយ៉ាងក្រៃលែង ។
- ព្រះអង្គបានបញ្ជាក់យ៉ាងច្បាស់ថា ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែល ត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងអរហត្តផល តែម្តងទេ ៕